# ករណីសិក្សាស្តីពីឧបករណ៍មិនបង្កទំនាស់

## គម្រោងសហគមន៍នេសាទ សេ អេហ្វ អេស ស៊ី និងជម្លោះនេសាទក្នុងឆកសមុទ្រកំពង់សោម

## ទិដ្ឋភាពទូទៅ

នៅដើមទសវត្សរ៍ឆ្នាំ ២០០០ គណៈកម្មាធិការសេវាកម្មមិត្តភាពអាមេរិក (AFSC) បានចាប់ផ្តើមគម្រោងសហគមន៍នេសាទក្នុងស្រុកស្រែអំបិល ខេត្តកោះកុង នៅភាគខាងជើងនៃឆកសមុទ្រកំពង់សោម។ សហគមន៍នេសាទចំនួន២ ត្រូវបានបង្កើតឡើងក្នុងស្រុកស្រែអំបិល គឺមួយនៅក្នុង ឃុំជីខក្រោម និង មួយទៀតនៅក្នុង ឃុំជ្រោយស្វាយ។ ក្នុងឆ្នាំ ២០០៤ អំពើហិង្សារវាងសហគមន៍នេសាទទាំងពីរត្រូវបានផ្ទុះឡើងយ ផ្ទះរបស់ពួកគេត្រូវបានលួចប្លន់ និងដុតបំផ្លាញ ហើយការិយាល័យកណ្តាលរបស់សហគមន៍នេសាទ ដែលគាំទ្រដោយ (AFSC) ត្រូវបានដុតបំផ្លាញចោលខ្ទេចខ្ទី។

**សម្គាល់៖** ករណីសិក្សានេះត្រូវបានរៀបចំឡើងក្នុងឆ្នាំ ២០១៧ ពោលគឺ ១៣ឆ្នាំ បន្ទាប់ពីហេតុការណ៍នេះបានកើតឡើង ដូចនេះការពិព័ណ៌នាប្រហែលជាមិនអាចរៀបរាប់អស់ពីហេតុការណ៍ជាក់ស្តែងដែលបានកើតឡើង។ អ្នកសរសេរ សូមអភ័យទោសទុកជាមុនសម្រាប់ចំណុចខ្វះខាតដែលកើតមានឡើង ហើយទោះបីជាយ៉ាងណាយើងសង្ឃឹមថា ករណីសិក្សានេះពិតជាចូលរួមចំណែកជួយដល់ការស្វែងយល់កាន់តែប្រសើរពី **ឧបករណ៍មិនបង្កទំនាស់**[1]។




## សាវតា

- នៅដើមទសវត្សរ៍ទី៩០ ការគ្រប់គ្រងរបស់រដ្ឋាភិបាលក្នុងស្រុកស្រែអំបិលនៅមានកម្រិតនៅឡើយ ក្នុងនោះការគ្រប់គ្រងតំបន់ព្រៃឈើដោយពួកខ្មែរក្រហមបន្តរហូតដល់ឆ្នាំ ១៩៩៦។ ការកាប់ឈើខុសច្បាប់មានការរីករាលដាលរហូតដល់ឆ្នាំ ១៩៩៩ ទើបត្រូវបានបង្ក្រាប។
- ប្រជានេសាទនៅស្រុកស្រែអំបិល បានប្រើប្រាស់ឧបករណ៍នេសាទតាមបែបប្រពៃណី ចាប់តាំងពីធ្លាក់ចូលក្នុងរបបខ្មែរក្រហមក្នុងឆ្នាំ ១៩៧៩។ ប្រជាពលរដ្ឋមួយចំនួនទៀត បានធ្វើស្រែចម្ការ ចិញ្ចឹមសត្វ កាប់ឈើខុសច្បាប់ និងជួញដូរសត្វព្រៃខុសច្បាប់។
- ក្រោយពីរដ្ឋាភិបាលបានសន្យាចំពោះជីវភាពរស់នៅរបស់អ្នកនេសាទ អ្នកចំណូលស្រុកដែលមកពីស្ទឹងហាវ នៅភាគខាងកើតនៃឆកសមុទ្រកំពង់សោមក៏បានចូលមកដល់ នៅចន្លោះឆ្នាំ ១៩៨៤ និង ១៩៨៧ ។ ពួកគេបានទិញកប៉ាល់នេសាទ និងកូនទូកវែងៗជាច្រើន។ ឆ្នាំ ១៩៨៧ ច្បាប់ជលផល ត្រូវបានបង្កើតឡើង ដែលធ្វើឲ្យការនេសាទរបស់ពួកគេនៅក្នុងតំបន់ទឹករាក់នៃឆកសមុទ្រកំពង់សោមក្លាយជាខុសច្បាប់។ ប៉ុន្តែពួកគេមិនមានជម្រើសផ្សេងទៀតក្នុងការចិញ្ចឹមជីវិតឡើយ។
- ច្បាប់ជលផល ឆ្នាំ ១៩៨៧ មិនបានរាប់បញ្ចូលបទប្បញ្ញត្តិសហគមន៍នេសាទទេ
- ទោះបីជាយ៉ាងណា រដ្ឋាភិបាលបានផ្តល់ការគាំទ្រដល់សហគមន៍នេសាទ ហើយនៅដើមទសវត្សរ៍ ២០០០ ច្បាប់ស្តីពីសហគមន៍នេសាទត្រូវបានពង្រាង[2]

---

[1] ករណីសិក្សានេះ ត្រូវបានពិព័ណ៌នាផងដែរក្នុង: គម្រោងរៀនសូត្ររួមគ្នារបស់ CDA “ឧបករណ៍មិនបង្កទំនាស់នៅកម្ពុជា” មេសា ២០១០ ទំព័រ ១៣ http://cdacollaborative.org/wordpress/wp-content/uploads/2016/02/Do-No-Harm-in-Cambodia.pdf

[2] អនុក្រឹតស្តីពីសហគមន៍នេសាទត្រូវបានអនុម័តនៅ ខែ មិថុនា ឆ្នាំ ២០០៥ ហើយច្បាប់ជលផលថ្មីត្រូវបានប្រកាស់ឲ្យប្រើនៅ ខែ ឧសភា ឆ្នាំ ២០០៦

- ក្រោយឆ្នាំ ១៩៩៩ អ្នកចំណូលថ្មីជាច្រើនដែលមកពីស្ទឹងហាវបានមកដល់ និងធ្វើនេសាទខុសច្បាប់។
- ប៉ុន្តែក្នុងទសវត្សរ៍ឆ្នាំ ២០០០ នាយកដ្ឋានជលផល ត្រូវបានបង្កើតឡើង ដើម្បីធ្វើការពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញានៅក្នុងវិស័យជលផល រួមជាមួយអាជ្ញាធរខេត្ត និងស្រុក។

# ទំនាស់សហគមន៍នេសាទ

ទំនាស់ជលផលបានចាប់ផ្តើមនៅឆ្នាំ ១៩៨៩។ អ្នកនេសាទបានអូសសំណាញ់របស់ពួកគេនៅតំបន់ទឹករាក់នៃឆកសមុទ្រកំពង់សោម ដោយរំលោភលើច្បាប់ជលផល ឆ្នាំ ១៩៨៧។ ទូកនេសាទភាគច្រើន មកពីស្ទឹងហាវក្នុងខេត្តព្រះសីហនុ និងមាននាវិកកម្ពុជាផលដែរ។ ទូកនេសាទផ្សេងទៀតមកពីប្រទេសថៃ និង វៀតណាម។ នៅពេលដែល កប៉ាល់នេសាទបានចូលមកដល់ អ្នកនេសាទក្នុងមូលដ្ឋាន នៅស្រុកស្រែអំបិលបានវាយបកវិញ ហើយជារឿយៗមានការលួចត្រីពីអួនកប៉ាល់នេសាទ។ ក្រុមនាវិកកប៉ាល់នេសាទ បានតបតវិញ។ នៅចន្លោះឆ្នាំ ១៩៨៩ និង ២០០២ ក្រុមនាវិកកប៉ាល់នេសាទ បានសម្លាប់អ្នកនេសាទចំនួន ២២ នាក់នៅតំបន់នោះ[3]។ ប៉ុន្តែនៅដើមទសវត្សរ៍ឆ្នាំ ២០០០ ដោយមានការពង្រឹងការគ្រប់គ្រងរបស់រដ្ឋាភិបាលក្នុងតំបន់ ទំនាស់ជលផលបានថយចុះ។

យ៉ាងណាក៏ដោយនៅឆ្នាំ ២០០៤ អំពើហឹង្សាថ្មីរវាងក្រុមអ្នកនេសាទបានផ្ទុះឡើង។ ក្រុមនាវិកមកពីស្ទឹងហាវ បានចូលលួចប្លន់ ដុតបំផ្លាញផ្ទះសម្បែង និងការិយាល័យកណ្តាលសហគមន៍នេសាទ នៅឃុំជីខក្រោម ដែលគាំទ្រដោយ AFSC ត្រូវបានដុតបំផ្លាញរាបដល់ដី។

**ទិដ្ឋភាពនៃទំនាស់រួមមាន៖**

- ជាទូទៅអាជ្ញាធរបានចាប់ខ្លួនអ្នកនេសាទតូចតាច ប៉ុន្តែមិនមែនប្រតិបត្តិករកប៉ាល់នេសាទធំៗនោះទេ
- នៅពេលកប៉ាល់នេសាទ ធ្វើនេសាទខុសច្បាប់ អ្នកនេសាទតូចតាចបានរឹបអូសឧបករណ៍នេសាទរបស់ពួកគេ
- នាវិកកប៉ាល់នេសាទ បានឆ្លើយតបដោយហិង្សា ដោយបានវាយប្រហារទៅលើអ្នកនេសាទតូចតាច និងបំផ្លាញឧបករណ៍នេសាទរបស់ពួកគេ។
- ពាក្យចចាមអារ៉ាម (ឧទាះ ស្តីអំពីអ្នកនេសាទស្រែអំបិល បានចាប់ជម្រិតអ្នកនេសាទស្ទឹងហាវ) នាំឱ្យមានអំពើហិង្សាកាន់តែធ្ងន់ធ្ងរឡើងៗ។
- អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការគាំទ្រដល់សហគមន៍នៅស្ទឹងហាវមានការយល់ឃើញ និង ទស្សនទានស្តីពីសិទ្ធិមនុស្ស ខុសពីការយល់ឃើញ និងទស្សនទានរបស់ AFSC ស្តីពីការការចិញ្ចឹមជីវិតប្រកបដោយចេរភាព។ ពួកគេបានឮរឿងរ៉ាវអំពីអ្នកនេសាទស្រែអំបិល ពីអ្នកនេសាទស្ទឹងហាវ ខុសពីអ្វីដែលបុគ្គលិករបស់ AFSC បានឮ។ ដូច្នេះ អង្គការមិនមនរដ្ឋាភិបាលរកឃើញថា វាមានការលំបាកណាស់ក្នុងការធ្វើការរួមគ្នា
- ទោះបីជាយ៉ាងណា អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានផ្សាភ្ជាប់យ៉ាងល្អ និងមានការគោរពយ៉ាងខ្លាំងពីសំណាក់សហគមន៍ ហើយពួកគេមានបំណងបង្កើនទំនាក់ទំនងរវាងសហគមន៍នេសាទទាំងពីរ
- អ្នកចំណូលថ្មីមិនសូវយកចិត្តទុកដាក់លើការថែរក្សាធនធានក្នុងស្រុក ដូចអ្នករស់នៅយូរអង្វែងទេ
- ក្រុមអ្នកនេសាទដែលជាគូប្រជែង បានកំណត់សហគមន៍របស់ពួកគេដោយខ្លួនឯង ហើយមានទំនាក់ទំនងតិចតួចបំផុតរវាងសហគមន៍ និងសហគមន៍ផ្សេងទៀត។
- ផ្ទះសម្បែងរបស់សហគមន៍នេសាទ គឺជានិមិត្តរូបនៃអំណាចរបស់ក្រុមសហគមន៍នេសាទ និងគោលដៅសម្រាប់ការវាយប្រហារ
- ទោះបីជាមានទំនាស់ក៏ដោយ អ្នកនេសាទទាំងអស់នៅជុំវិញឆកកំពង់សោម មានចំណាប់អារម្មណ៍រួមគ្នាលើនិរន្តរភាពនៃការនេសាទ "ប្រសិនបើត្រីបាត់បង់អស់ អ្នកទាំងអស់គ្នានឹងរងគ្រោះ"
- រដ្ឋាភិបាលខេត្តកោះកុង និងព្រះសីហនុ មានឆន្ទៈប្រមូលអ្នកពាក់ព័ន្ធមកពិភាក្សារួមគ្នា

[3] កាសែតភ្នំពេញប៉ុស្តិ៍ “ការបោះឆ្នោតដោយសម្ងាត់សម្រាប់ជលផលខេត្តកោះកុង” ១៨ កក្កដា ២០០៣

http://www.phnompenhpost.com/national/election-bait-koh-kong-fisheries